00847574



ព្រះរាជាណាចក្រកម្ពុជា E138/1/10/1/2/3.1

ជាតិ សាសនា ព្រះមហាក្សត្រ

********

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 01-Oct-2012, 11:48
CMS/CFO: Krystal THOMPSON

មន្ទីរឃុំឃាំង អ.វ.ត.ក
ទទួល
លេខ 173 ...
ថ្ងៃទី 16 ខែកញ្ញា ឆ្នាំ 2012
ម៉ោង 10...

សាលាដំបូងរាជធានីភ្នំពេញ

លេខ: ២៨៨ (ឌ)

# ដីកាសម្រេច

យើង គូ ពៅស៊ុន ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញមាត្រា ៣ និងមាត្រាពាក់ព័ន្ធ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង ។

-បានឃើញមាត្រា ២៤ និងមាត្រា ១១០៤ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី ។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ: ១៦៣៨ ចុះថ្ងៃទី ១៣-០៩-២០១២ ។

-បានឃើញពាក្យសុំប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅចុះថ្ងៃទី ១៣-០៩-២០១២ របស់អ្នកប្តឹងសុំលោកព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ អាស័យដ្ឋានអាគារលេខ ២៥-២៧ ផ្លូវលេខ ២១៧-២១៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

ដែលមានកម្មវត្ថុ: សុំឲ្យតុលាការចេញដីកាសម្រេច:

១-ជ្រើសតាំងឈ្មោះ អៀង វិជីដា ជាអ្នកអាណាព្យាបាលទូទៅលើឈ្មោះ អៀង ធីរិទ្ធ ។

២-ឲ្យអ្នកអាណាព្យាបាលទូទៅឈ្មោះ អៀង វិជីដា ថែរក្សាឈ្មោះ អៀង ធីរិទ្ធ ដោយឲ្យស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងជូនដំណឹងដល់ការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក មុននឹងផ្លាស់ប្តូរអាស័យដ្ឋានរស់នៅទីណាមួយរបស់ឈ្មោះ អៀង ធីរិទ្ធ ។

-បានឃើញពាក្យសុំយកម្តាយទៅថែរក្សារបស់លោកស្រី អៀង វិជីដា ចុះថ្ងៃទី ១៣-០៩-២០១២ ។

-បានឃើញសំណុំរឿងលេខ ០០២/១៩ កញ្ញា ឆ្នាំ២០០៧/អវតក/អជសជ របស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

-បានឃើញរបាយការណ៍សង្ខេបរបស់អ្នកជំនាញពាក់ព័ន្ធនឹង អៀង ធីរិទ្ធ ចុះថ្ងៃទី ២៩-០៨-២០១២ ។

-យោងសេចក្តីសម្រេច លើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣-១២-២០១១ របស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ១៣-០៩-២០១២ ។

## សាលាដំបូងរាជធានីភ្នំពេញ

## សំអាងហេតុ

១-ពាក្យសុំប្រកាសចាប់ផ្តើមអ្នកអាណាព្យាបាលទូទៅលើឈ្មោះ អៀង ធីរិទ្ធ ចុះថ្ងៃទី ១៣-០៩-២០១២ របស់អ្នកប្តឹងសុំលោកព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី

ភ្នំពេញ និងរបស់ឈ្មោះ អៀង វិជីដា មានលក្ខណៈត្រឹមត្រូវតាមមាត្រា ២៦ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង ។

២-តាមការអះអាងរបស់អ្នកប្តឹងសុំ លោកព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថាៈ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានសម្រេចដោះលែងឈ្មោះ អៀង ធីរិទ្ធ ដោយមូលហេតុគាត់មានជម្ងឺវើវាយ បាត់បង់ការចងចាំ ដើម្បីងាយស្រួលគ្រប់គ្រង ជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធភាពតាមផ្លូវច្បាប់នៃសកម្មភាពរបស់ឈ្មោះ អៀង ធីរិទ្ធ ដោយមានវិបត្តិផ្នែកស្មារតី តាមការបញ្ជាក់នៅក្នុងរបាយការណ៍សង្ខេបរបស់អ្នកជំនាញ ទើបលោកព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញប្តឹងសុំឲ្យប្រកាសការចាប់ផ្តើមអ្នកអាណាព្យាបាលទូទៅលើឈ្មោះ អៀង ធីរិទ្ធិ តាមច្បាប់ ។ តាមការអះអាងនេះស្របនឹងពាក្យសុំរបស់ឈ្មោះ អៀង វិជីដា ហើយស្របនឹងរបាយការណ៍សង្ខេបរបស់អ្នកជំនាញពាក់ព័ន្ធនឹង អៀង ធីរិទ្ធ ចុះថ្ងៃទី ២៩-០៨-២០១២ របស់វេជ្ជបណ្ឌិត Seena Fazel អ្នកស្រាវជ្រាវជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រព្យាបាលជម្ងឺ និងជាវេជ្ជបណ្ឌិតពិគ្រោះយោបល់កិត្តិយសផ្នែកវិកលវិទ្យានីតិវេជ្ជសាស្ត្រសាកលវិទ្យាល័យ OXFord ចក្រភពអង់គ្លេស , សាស្ត្រាចារ្យ John CAMPBELL សាស្ត្រាចារ្យជំនាញព្យាបាលរោគមនុស្សចាស់នៃសាកលវិទ្យាល័យអូតាហ្គូសប្រទេសណូវែលហ្សឺឡង់ និងវេជ្ជបណ្ឌិត ហួត លីនណា ជាសាស្ត្រាចារ្យរងផ្នែកវិកលវិទ្យា នៃសាកលវិទ្យាល័យអន្តរជាតិ , ប្រធានផ្នែកពិគ្រោះជម្ងឺផ្លូវចិត្ត នៃមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា សន្និដ្ឋានថាៈ លោកស្រី អៀង ធីរិទ្ធ ពិតជាមានជម្ងឺវង្វេងស្មារតីក្នុងកម្រិត មធ្យមទៅធ្ងន់ធ្ងរ ។

៣-ឈ្មោះ អៀង វិជីដា ភេទស្រី អាយុ ៥១ឆ្នាំ មុខរបរ គ្រូពេទ្យ [redacted] ជាកូនបង្កើតរបស់ឈ្មោះ អៀង ធីរិទ្ធ ។

៤-ឈ្មោះ អៀង ធីរិទ្ធ មានជម្ងឺវើវាយស្មារតី បាត់បង់ការចងចាំដែលតំរូវឲ្យអ្នកអាណាព្យាបាលទូទៅមានកាតព្វកិច្ចដើម្បីយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់ដោយមិនឲ្យជននេះទៅទីណាដោយមិនដឹង ។

៥-ដោយផ្អែងតាមសំអាងហេតុខាងលើគប្បីតុលាការសម្រេចតាមពាក្យសុំរបស់អ្នកប្តឹងសុំ ។

## ហេតុដូច្នេះសំរេច

១-ជ្រើសតាំងឈ្មោះ អៀង វិជីដា ជាអ្នកអាណាព្យាបាលទូទៅលើឈ្មោះ អៀង ធីរិទ្ធ ។

២-ឲ្យអ្នកអាណាព្យាបាលទូទៅឈ្មោះ អៀង វិជីដា ថែរក្សាឈ្មោះ អៀង ធីរិទ្ធ ដោយឲ្យស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងជូនដំណឹងដល់ការិយាល័យរដ្ឋបាលនៃអ.វ.ត.ក មុននឹងផ្លាស់ប្តូរអាស័យដ្ឋានរស់នៅទីណាមួយរបស់ឈ្មោះ អៀង ធីរិទ្ធ ។

-រក្សាសិទ្ធិប្តឹងជំទាស់ក្នុងកំណត់ច្បាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ...14... ខែ កញ្ញា ឆ្នាំ២០១២

ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

ភួ_ពៅស៊ិន